

# ពង្រឹងសហគមន៍ ជាតិរឹងមាំ
## (ពាក្យស្លោកអង្គការអោយស៊ីស៊ី)

*មេឃុំម្នាក់ក្នុងខេត្តស្វាយរៀងបាននិយាយថា "អ្វីដែលពួកគេបានធ្វើ (អោយស៊ីស៊ី-គម្រោងហ្វាស) ល្អសម្រាប់ប្រជាពលរដ្ឋនៅក្នុងភូមិ និងក្នុងឃុំ" ។ មុនពេល អាយស៊ីស៊ី-គម្រោង ហ្វាស(អភិវឌ្ឍន៍គ្រួសារ និងសាលារៀន) បានមកធ្វើការក្នុងខេត្តស្វាយរៀង ប្រជាជននៅក្នុងសហគមន៍មិនសូវមានសកម្មភាពធ្វើរបរស៊ីនៅតាមផ្ទះ ដូចជាការដាំដំណាំ ការចិញ្ចឹមសត្វ និងការដាំដុះស្រូវតាមបច្ចេកទេសកសិកម្មទំនើបនោះទេ។ ម៉្យាងទៀត ការអនុវត្តអនាម័យរបស់ប្រជាពលរដ្ឋ នៅមិនទាន់បានល្អនៅ ឡើយ។ ហើយក៏នៅមានការសហការតិចតួចក្នុងចំណោមប្រជាពលរដ្ឋក្នុងការបង្កើតជាដើមទុនក្នុងភូមិ។ គ្រួសារភាគច្រើននៅក្នុងសហគមន៍ធ្លាប់ត្រូវបានប្រឈមនឹងកង្វះខាតម្ហូបអាហារ ពីមួយខែទៅបីខែក្នុងមួយមួយឆ្នាំ ហើយគ្រួសារភាគច្រើនគឺត្រូវពឹងផ្អែកលើការចំណាកស្រុក។ លើសពីនេះទៅទៀត កុមារក្នុងសហគមន៍ធ្លាប់ត្រូវបានប្រឈមនឹងកង្វះអាហារូបត្ថម្ភ និងអត្រាខ្ពស់នៃការមិនបានចុះឈ្មោះចូលរៀន និងការបោះបង់ចោលការសិក្សា។*

ការពិពណ៌នាខាងលើ គឺបានដក់ស្រង់ចេញពីរបាយការណ៍វាយតម្លៃខាងក្រៅ ដែលបានធ្វើឡើងនៅខែធ្នូ ឆ្នាំ២០១៨ សម្រាប់គម្រោងហ្វាស។ គម្រោង ហ្វាស បានចាប់ផ្តើមដំណើរការនៅខេត្តស្វាយរៀង ចាប់តាំងពីឆ្នាំ ២០១២ ដែលផ្តោតសំខាន់ទៅលើការលើកកម្ពស់សុខុមាលភាពគ្រួសារក្នុងសហគមន៍ ទាក់ទងទៅនឹងការកាត់បន្ថយភាពក្រីក្រ ការពង្រឹងស្មារតីទៅដល់សហគមន៍ និងការអប់រំភាពជាពលរដ្ឋ។

ក្រុមជួយខ្លួនឯង ត្រូវបានបង្កើតឡើង ហើយឥឡូវនេះសមាជិកនិងកសិករគំរូមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ក្នុងក្រុមគ្រួសារ និងសម្រាប់លក់។ ក្រុមគោលដៅភាគច្រើនដែលនៅក្នុងសហគមន៍ បានកំពុងនឹងធ្វើការដាំដុះបន្លែ ចិញ្ចឹមសត្វ និងដាំស្រូវតាមបច្ចេកទេសកសិកម្មទំនើប។ លោកគ្រូអ្នកគ្រូ និងនាយកសាលាបានចាប់ផ្តើមកត់សំគាល់សមត្ថភាពរបស់ឪពុកម្តាយ ក្នុងការជួយផ្គត់ផ្គង់កូនៗរបស់ពួកគាត់ឱ្យបានទៅសាលារៀន ដោយសារតែសិស្សានុសិស្សមានមធ្យោបាយធ្វើដំណើរ មានឯកសណ្ឋាន និងសម្ភារៈសិក្សាគ្រប់គ្រាន់។ ក្រុមគោលដៅនៅក្នុងសហគមន៍ ក៏កាន់តែដឹងច្បាស់អំពីបញ្ហាសង្គម ឧទាហរណ៍ដូចជាតាមរយៈការបណ្តុះបណ្តាល និងការផ្លាស់ប្តូរទស្សនកិច្ចសិក្សាទៅភូមិគំរូដទៃទៀត។ ទន្ទឹមនឹងនេះ គម្រោងហ្វាស បានពង្រឹងតួនាទី និងភារៈកិច្ចរបស់អាជ្ញាធរមូលដ្ឋាន និងមន្ទីរដ៏ទៃទៀត តាមរយៈការតភ្ជាប់បណ្តាញ និងការហ្វឹកហាត់ ដើម្បីឱ្យពួកគេមានភាពសកម្មក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍។ គម្រោងហ្វាស ក៏បានពង្រឹងស្មារតីផងដែរ ទៅដល់សហគមន៍គោលដៅ ដើម្បីឱ្យមានភាពជាម្ចាស់នៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សហគមន៍របស់ពួកគេ។ ទាំងអស់នេះគឺជួយឱ្យសហគមន៍ទាំងនោះអាចឈរដោយខ្លួនឯងបាន ហើយដើម្បីឱ្យសង្គមស៊ីវិលមាននិរន្តរភាពយូរអង្វែង។

គម្រោងហ្វាស គឺមានភាពផ្សារភ្ជាប់ជាប់ខ្លាំងជាមួយនឹង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ) ដែលបង្ហាញពីសារៈសំខាន់ និងយុទ្ធសាស្ត្រផ្សេងៗសម្រាប់កាត់បន្ថយភាពក្រីក្រនៅកម្រិតគ្រួសារ។ លើសពីនេះទៀត គម្រោងហ្វាស បាននឹងកំពុងលើកកម្ពស់ គោលនយោបាយអភិវឌ្ឍន៍យុវជនកម្ពុជា តាមរយៈការកៀរគរ និងពង្រឹងស្មារតីរបស់យុវជនតាមរយៈការប្រមូលផ្តុំពួកគេជាក្លឹបយុវជន។ នៅក្នុងក្លឹបយុវជន ពួកគាត់ បានរៀនសូត្រនូវបំណិនជីវិតសំខាន់ៗ ហើយពួកគេនឹងកំពុងចូលរួមគ្នាយ៉ាងសកម្មក្នុងកិច្ចការសហគមន៍។ គម្រោងហ្វាស ក៏បានបង្កើតនូវកិច្ចសហការដ៏ល្អជាមួយនឹងអាជ្ញាធរពាក់ព័ន្ធ ដើម្បីកាត់បន្ថយអត្រាបោះបង់ចោលការសិក្សា និងដើម្បីលើកកម្ពស់ការអប់រំដែលមានគុណភាព ក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងកំលាំងពលកម្មកុមារ។ ដោយបានធ្វើការដោយផ្ទាល់ជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន គម្រោងហ្វាស កំពុងរួមចំណែកបង្កើនភាពរឹងមាំដល់ប្រទេសកម្ពុជា ដូចមាននៅក្នុងពាក្យស្លោករបស់អង្គការអោយស៊ីស៊ី។

ហេតុមកដល់ពេលនេះ គម្រោងហ្វាស បានរួមចំណែកយ៉ាងសំខាន់ឆ្ពោះទៅកាន់លទ្ធផល និងផលប៉ះពាល់ដែលបានរំពឹងទុក។ គិតមកដល់ពេលនេះ នៅសល់តែមួយឆ្នាំទៀតតែប៉ុណ្ណោះសម្រាប់គម្រោងហ្វាស ហើយដំណាក់កាលនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីធានាឱ្យបាននូវនិរន្តរភាពសម្រាប់រយៈពេលវែងតាមរយៈលទ្ធផលដែលបានសម្រេចបាន។ របាយការណ៍ដែលបានមកពីការវាយតម្លៃខាងក្រៅនេះបានបញ្ជាក់ថា គម្រោងហ្វាស ឆ្លើយតបនិងត្រូវនឹងតម្រូវការរបស់សហគមន៍នៅក្នុងខេត្តស្វាយរៀងពិតប្រាកដមែន។ គម្រោងនេះ នឹងបន្តធ្វើការជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន សម្រាប់ដំណាក់កាលបន្ទាប់ទៀត ដើម្បីជួយអន្តរាគមន៍ទាក់ទងទៅនឹងតម្រូវការផ្សេងទៀតៗ ក៏ដូចជាអន្តរាគមន៍ទាក់ទងទៅនឹងបញ្ហាសង្គម និងការអភិវឌ្ឍនៅក្នុងខេត្តស្វាយរៀងផងដែរ។

កាលបរិច្ឆេទៈ មីនា ២០១៩